គណបក្ស សម រង្ស៊ី
SAM RAINSY PARTY
PARTI SAM RAINSY
សីលធម៌ សច្ចធម៌ យុត្តិធម៌

# សេចក្តីណែនាំ
## ស្តីពី
## បែបបទ និងនីតិវិធីនៃការបោះឆ្នោតជ្រើសតាំងប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ការជ្រើសរើសបេក្ខជនក្រុមប្រឹក្សាឃុំ-សង្កាត់ និងបេក្ខជនតំណាងរាស្ត្រ

យោងលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងគណបក្ស បទបញ្ជាស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃរចនាសម្ព័ន្ធគណបក្សមូលដ្ឋាននិងខេត្ត-ក្រុង និងយោងសភាពការណ៍ជាក់ស្តែង គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស សូមធ្វើការណែនាំ ស្តីពីបែបបទ និងនីតិវិធីនៃការបោះឆ្នោតជ្រើសតាំងប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ការជ្រើសរើសបេក្ខជនក្រុមប្រឹក្សាឃុំ-សង្កាត់ និងបេក្ខជនតំណាងរាស្ត្រ ដូចខាងក្រោម :

### I_ការជ្រើសតាំងប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង

ប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ត្រូវបានជ្រើសតាំងដោយសមាជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងសាមី ប្រធានក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ និងប្រធានក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌនៅក្នុងខេត្ត-ក្រុងសាមី តាមរយៈការបោះឆ្នោតសម្ងាត់ ដោយសម្លេងភាគច្រើនដាច់ខាតនៃអ្នកមានសិទ្ធិបោះឆ្នោតទាំងអស់ សំរាប់អាណត្តិ ៣ឆ្នាំ ។ អាណត្តិរបស់ប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ត្រូវបញ្ចប់នៅពេលដែលប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងថ្មី មកជំនួស ។

កាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសតាំងប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ត្រូវកំណត់ដោយអគ្គលេខាធិការគណបក្ស រយៈពេលយ៉ាងយូរពីរខែមុនផុតអាណត្តិ ឲ្យស្របជាមួយនឹងកាលបរិច្ឆេទនៃសមាជគណបក្សខេត្ត-ក្រុង ។

កិច្ចប្រជុំនៃការបោះឆ្នោតជ្រើសតាំងប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង យកជាការបានចាំបាច់ត្រូវមានកូរ៉ុម៦ភាគ១០ នៃអ្នកមានសិទ្ធិបោះឆ្នោតទាំងអស់ ។

ប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង បំពេញការងាររបស់ខ្លួនយ៉ាងច្រើនពីរអាណត្តិ នៅក្នុងខេត្ត-ក្រុងតែមួយ ។ ក្នុងករណីប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងរូបណាដែលដឹកនាំការងារគណបក្សឲ្យទទួលបានជ័យជំនះ ដោយអាសនៈសមាជិករដ្ឋសភានៅក្នុងខេត្ត-ក្រុងនោះកើនឡើង ប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងរូបនោះ អាចឈរឈ្មោះជាបេក្ខជនប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងសាមីជាថ្មីទៀតបាន ។

#### ១_សិទ្ធិឈរឈ្មោះជាបេក្ខជនប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង

សមាជិកសកម្មគណបក្សដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម :



ទីស្នាក់ការកណ្តាល : ផ្ទះលេខ ៧១ មហាវិថីសម្តេចសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Headquarters : House # 71 Sothearos Road, Phnom Penh, Kingdom of Cambodia
Tel : (855-23) 217 452 / 211 336 Fax : (855-23) 217 452 / 211 336
**E-mail address :** srphqpp@forum.org.kh, cabinet@samrainsyparty.org

_ជាសមាជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងសាមី ដែលជឿជាក់លើគោលការណ៍ និងគោលនយោបាយគណបក្ស មានកេរ្តិ៍ឈ្មោះល្អ មានសុភវិនិច្ឆ័យ ចូលរួមយ៉ាងសកម្មទាំងកម្លាំងកាយ ប្រាជ្ញា ថវិកា និងពេលវេលាជួយការងារគណបក្សខេត្ត-ក្រុងប្រកបដោយប្រសិទ្ធភាព ដូចជាដឹកនាំការងារគណបក្សខេត្ត-ក្រុង ឬស្រុក-ខណ្ឌឲ្យទទួលបានជោគជ័យក្នុងការបោះឆ្នោតឃុំ-សង្កាត់ ឬបោះឆ្នោតជាតិ

_មានកំរិតវប្បធម៌ថ្នាក់ឧត្តមសិក្សា ឬមានបទពិសោធន៍លើការងារគ្រប់គ្រង ដឹកនាំ និងយល់ដឹងទូលំទូលាយអំពីបញ្ហាសង្គម និងនយោបាយ

សមាជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងរូបណា ដែលមានបំណងឈរឈ្មោះជាបេក្ខជនប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ត្រូវដាក់ពាក្យសុំឈរឈ្មោះជាបេក្ខជន មកគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស តាមរយៈអគ្គលេខាធិការគណបក្ស យ៉ាងតិច១ខែមុនការបោះឆ្នោត ។ គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្សត្រូវពិនិត្យលើពាក្យសុំនេះ ។ បើបេក្ខជនរូបណាបានបំពេញតាមលក្ខខណ្ឌខាងលើ គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស ត្រូវបញ្ជូនឈ្មោះបេក្ខជនទាំងអស់នោះទៅអគ្គលេខាធិការគណបក្ស ដើម្បីរៀបចំការបោះឆ្នោតតាមនីតិវិធីដែលបានកំណត់ ។

ក្នុងករណីដែលបេក្ខជនប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងណា មិនបានបំពេញតាមលក្ខខណ្ឌខាងលើ ប្រធានគណបក្សអាចស្នើសុំឲ្យសមាជិកមួយរូប ឬច្រើនរូប នៃក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងផ្សេងទៀត ទៅឈរឈ្មោះជាបេក្ខជនប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងនោះ ។

សមាជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ដែលទទួលស្គាល់ដោយប្រធានគណបក្ស ប្រធានក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌ និងប្រធានក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់នៃខេត្ត-ក្រុងសាមី ដែលទទួលស្គាល់ដោយអគ្គលេខាធិការគណបក្ស មានសិទ្ធិចូលរួមក្នុងការបោះឆ្នោតជ្រើសតាំងប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងនោះ ។

បើលទ្ធផលនៃការបោះឆ្នោតនៅជុំទី១ ពុំមានបេក្ខជនណាមួយទទួលបានសម្លេងគាំទ្រជាប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង គណៈកម្មការរៀបចំការបោះឆ្នោតត្រូវរៀបចំការបោះឆ្នោតជុំទី២ ដោយជ្រើសរើសយកបេក្ខជនតែពីររូបដែលទទួលបានសម្លេងឆ្នោតច្រើនជាងគេ ទៅប្រកួតប្រជែង ។ ក្នុងករណីដែលបេក្ខជនទី២ និងទី៣ បានសម្លេងឆ្នោតស្មើគ្នា បើបេក្ខជននោះជាបុរស និងស្ត្រី អាទិភាពត្រូវបានទៅស្ត្រី, បើបេក្ខជននោះ មានភេទដូចគ្នា ត្រូវធ្វើការចាប់ឆ្នោត ។

បើលទ្ធផលនៃការបោះឆ្នោតនៅជុំទី២នេះ ពុំមានបេក្ខជនណាមួយទទួលបានសម្លេងគាំទ្រភាគច្រើនដាច់ខាតនៃចំនួនអ្នកមានសិទ្ធិបោះឆ្នោតទាំងអស់ គណៈកម្មការរៀបចំការបោះឆ្នោតត្រូវជ្រើសរើសយកបេក្ខជនមួយរូបដែលទទួលបានសន្លឹកឆ្នោតច្រើនជាងគេ (ឬជ្រើសរើសយកបេក្ខជនស្ត្រី ឬវិធីចាប់ឆ្នោតបើភេទដូចគ្នា ក្នុងករណីបេក្ខជនទាំងពីររូបទទួលបានសម្លេងស្មើគ្នា) ទៅបោះឆ្នោតជុំទី៣បន្តទៀត ។ នៅជុំទី៣នេះ បើបេក្ខជនរូបនោះពុំបានទទួលសម្លេងគាំទ្រជាប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងទេ គណៈកម្មការរៀបចំការបោះឆ្នោតត្រូវលើកពេលនៃការបោះឆ្នោត ហើយធ្វើរបាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស ដើម្បីសុំគោលការណ៍សំរាប់ការបោះឆ្នោតលើកក្រោយ ។

**២_ការគ្រប់គ្រងការបោះឆ្នោត**

ការបោះឆ្នោតជ្រើសតាំងប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ត្រូវដឹកនាំដោយគណៈកម្មការរៀបចំការបោះឆ្នោតមួយ ដែលមានសមាសភាពដូចតទៅ :

ក_អគ្គលេខាធិការគណបក្ស ឬអគ្គលេខាធិការរងគណបក្ស ជាប្រធាន

ខ_សមាជិកគណៈកម្មាធិការនាយកគណបក្សចំនួន២រូប ជាជំនួយការ

គណៈកម្មការរៀបចំការបោះឆ្នោត ត្រូវតែងតាំងសមាជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងសាមីពីររូប ដើម្បីធ្វើរបាយការណ៍អំពីលទ្ធផលនៃការបោះឆ្នោត ។

គណៈកម្មការនេះ ត្រូវធានានាដំណើរការ និងការប្រព្រឹត្តទៅនៃការរៀបចំការបោះឆ្នោត ឲ្យមានតម្លាភាព និងយុត្តិធម៌ ស្របតាមបទបញ្ញត្តិជាធរមានរបស់គណបក្ស ។

**៣_ការប្តឹងជំទាស់លើលទ្ធផលនៃការបោះឆ្នោត :**

**ក_ការប្តឹងជំទាស់លើលទ្ធផលបឋម**

បេក្ខជនប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងរូបណា ដែលមិនសុខចិត្តនឹងលទ្ធផលនៃការបោះឆ្នោតបឋម ដោយមានហេតុផលច្បាស់លាស់ មានសិទ្ធិប្តឹងជំទាស់ភ្លាមជាលាយលក្ខណ៍អក្សរមកគណៈកម្មការរៀបចំការបោះឆ្នោត ។ គណៈកម្មការរៀបចំការបោះឆ្នោត ត្រូវពិនិត្យ និងដោះស្រាយពាក្យបណ្តឹងភ្លាម បន្ទាប់ពីទទួលពាក្យបណ្តឹងជំទាស់ ។ បើរកឃើញថា ការបោះឆ្នោតនោះមានភាពមិនប្រក្រតី ខុសនីតិវិធី គណៈកម្មការរៀបចំការបោះឆ្នោត ត្រូវរៀបចំដំណើរការបោះឆ្នោតសារជាថ្មីឡើងវិញ ។ ផ្ទុយទៅវិញ បើគណៈកម្មការរៀបចំការបោះឆ្នោតពិនិត្យឃើញថាមិនមានកំហុសឆ្គង ឬភស្តុតាងណាមួយ ដែលនាំឲ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត គណៈកម្មការរៀបចំការបោះឆ្នោតត្រូវប្រកាសលទ្ធផលជាផ្លូវការ ដោយទុករយៈពេលបីថ្ងៃសំរាប់បើកផ្លូវតវ៉ា មកគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស ។

**ខ_ការប្តឹងតវ៉ា**

គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស ត្រូវដោះស្រាយវិវាទនៃការបោះឆ្នោតជ្រើសតាំងប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងក្នុងរយៈពេលយ៉ាងយូរ៧ថ្ងៃបន្ទាប់ពីទទួលពាក្យបណ្តឹង ។ សេចក្តីសំរេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ជាសេចក្តីសំរេចចុងក្រោយបិទផ្លូវតវ៉ា ។

**៤_ថវិកាសំរាប់រៀបចំការបោះឆ្នោត**

ថវិកាសំរាប់ចំណាយក្នុងការរៀបចំការបោះឆ្នោតជ្រើសតាំងប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ត្រូវធានារ៉ាប់រងដោយក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ។

## II_ការជ្រើសរើសបេក្ខជនក្រុមប្រឹក្សាឃុំ-សង្កាត់

**១_លក្ខខណ្ឌសំរាប់ការឈរឈ្មោះជាបេក្ខជនក្រុមប្រឹក្សាឃុំ-សង្កាត់**

ដើម្បីមានសិទ្ធិឈរឈ្មោះជាបេក្ខជនក្រុមប្រឹក្សាឃុំ-សង្កាត់ សមាជិកគណបក្សគ្រប់រូបត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម :

_ជាសមាជិកគណបក្សដែលមានអាយុ២៥ឆ្នាំឡើង មានទីលំនៅ និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៅក្នុងឃុំ-សង្កាត់សាមី ហើយដែលមានជំនឿជឿជាក់លើគោលការណ៍ និងគោលនយោបាយគណបក្ស មានប្រជាប្រិយភាពចេះឈឺឆ្អាលក្នុងការជួយដោះស្រាយបញ្ហាអ្នកដទៃ ចូលរួមយ៉ាងសកម្មទាំងកម្លាំងកាយ ប្រាជ្ញា ស្មារតី ថវិកា និងពេលវេលា ក្នុងការជួយការងារគណបក្សភូមិ ឬឃុំ-សង្កាត់ ដូចជាការបង្កើនសមាជិកគណបក្សនៅក្នុងភូមិ ព្រមទាំងការនាំប្រជាពលរដ្ឋនៅក្នុងភូមិនីមួយៗទៅធ្វើអត្តសញ្ញាណប័ណ្ណ និងទៅចុះឈ្មោះបោះឆ្នោតជាដើម ។

_ចេះអាន និងសរសេរអក្សរខ្មែរ មានការយល់ដឹងអំពីប្រជាសាស្ត្រ ជីវភាពរបស់ប្រជាពលរដ្ឋនៅក្នុងភូមិ ឃុំ-សង្កាត់ និងយល់ដឹងអំពីសង្គម និងនយោបាយ ។

សមាជិកគណបក្សដែលមានបំណងឈរឈ្មោះជាបេក្ខជនក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវដាក់ពាក្យសុំឈរឈ្មោះមកគណៈកម្មការគណបក្សស្រុក-ខណ្ឌរៀបចំបញ្ជីបេក្ខជនក្រុមប្រឹក្សាឃុំ-សង្កាត់ តាមរយៈប្រធានក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់សាមី ។ ទំរង់បែបបទនៃពាក្យសុំឈរឈ្មោះជាបេក្ខជន កំណត់ដោយអគ្គលេខាធិការគណបក្ស ។

**២_ការជ្រើសរើស និងការរៀបចំបញ្ជីលំដាប់លេខរៀងបេក្ខជនក្រុមប្រឹក្សាឃុំ-សង្កាត់**

ការជ្រើសរើស និងការរៀបចំបញ្ជីលំដាប់លេខរៀងបេក្ខជនក្រុមប្រឹក្សាឃុំ-សង្កាត់ ជាសមត្ថកិច្ចរបស់គណៈកម្មការគណបក្សស្រុក-ខណ្ឌរៀបចំបញ្ជីបេក្ខជនក្រុមប្រឹក្សាឃុំ-សង្កាត់ ។ គណៈកម្មការគណបក្សស្រុក-ខណ្ឌរៀបចំបញ្ជីបេក្ខជនក្រុមប្រឹក្សាឃុំ-សង្កាត់មានសមាសភាពដូចតទៅ :

ក_ប្រធានក្រុមទ្រទ្រង់ការងារគណបក្សប្រចាំស្រុក-ខណ្ឌសាមី ឬតំណាង ជាប្រធាន

(ក្នុងករណីស្រុក-ខណ្ឌណាពុំទាន់មានក្រុមទ្រទ្រង់ការងារគណបក្ស សមាជិកមួយរូបនៃក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ធ្វើជាប្រធានគណៈកម្មការ)

ខ_តំណាងមួយរូបនៃក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌសាមី ជាអនុប្រធាន

គ_តំណាងមួយរូបនៃចលនាយុវជនជាតិខ្មែរ និងតំណាងមួយរូបនៃចលនាស្ត្រីជាតិខ្មែរប្រចាំស្រុក-ខណ្ឌសាមី ជាសមាជិក ។

ក្នុងករណីស្រុក-ខណ្ឌណា ដែលមិនទាន់រៀបចំចលនាយុវជនជាតិខ្មែរ និងចលនាស្ត្រីជាតិខ្មែរ សមាសភាពគណៈកម្មការនេះ ត្រូវជំនួសដោយតំណាងពីររូបទៀតនៃក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌ ។

សមាសភាពទាំងអស់នៃគណៈកម្មការនេះ ជាបុគ្គលដែលមិនមែនជាបេក្ខជនក្រុមប្រឹក្សាឃុំ-សង្កាត់ ហើយតែងតាំងដោយប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងសាមី ។

**២-១_ការជ្រើសរើសបេក្ខជនក្រុមប្រឹក្សាឃុំ-សង្កាត់ :**

គណៈកម្មការគណបក្សស្រុក-ខណ្ឌរៀបចំបញ្ជីបេក្ខជនក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវពិនិត្យ និង សំរេចលើពាក្យ ដែលសមាជិកគណបក្សបានសុំឈរឈ្មោះជាបេក្ខជនក្រុមប្រឹក្សាឃុំ-សង្កាត់ ដោយផ្អែកលើគោលវិនិច្ឆ័យខាងលើ ។ បើបេក្ខជនរូបណាបានបំពេញតាមលក្ខខណ្ឌខាងលើហើយ គណៈកម្មការគណបក្សស្រុក-ខណ្ឌរៀបចំបញ្ជីបេក្ខជនក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវឲ្យបេក្ខជនរូបនោះបំពេញទំរង់ បែបបទ ដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ចំពោះឃុំ-សង្កាត់ណាដែលមានសមាជិកគណបក្សសុំឈរឈ្មោះជាបេក្ខជនក្រុមប្រឹក្សាឃុំ-សង្កាត់ មានចំនួនតិចជាងចំនួនបេក្ខជនដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ គណៈកម្មការគណបក្សស្រុក-ខណ្ឌរៀបចំបញ្ជីបេក្ខជនក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវសហការជាមួយក្រុមប្រឹក្សាគណបក្សភូមិ និងក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់សាមី ធ្វើការជ្រើសរើសបេក្ខជនដែលមានលក្ខណសម្បត្តិសមស្របបន្ថែម ដើម្បីបំពេញបញ្ជីបេក្ខជនដែលច្បាប់បានកំណត់ ។

ផ្ទុយទៅវិញ ចំពោះឃុំ-សង្កាត់ណាដែលមានសមាជិកគណបក្សសុំឈរឈ្មោះជាបេក្ខជនក្រុមប្រឹក្សាឃុំ-សង្កាត់ ហើយបានបំពេញតាមលក្ខខណ្ឌខាងលើ មានចំនួនច្រើនជាងចំនួនបេក្ខជនដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ គណៈកម្មការគណបក្សស្រុក-ខណ្ឌរៀបចំបញ្ជីបេក្ខជនក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវ :

_សហការជាមួយក្រុមប្រឹក្សាគណបក្សភូមិ និងក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់សាមី ដើម្បីសម្របសម្រួល រកបេក្ខជនណាដែលស្ម័គ្រចិត្តដកខ្លួនចេញពីការឈរឈ្មោះជាបេក្ខជនក្រុមប្រឹក្សាឃុំ-សង្កាត់ ឬ

_រៀបចំធ្វើការបោះឆ្នោតជ្រើសរើសបេក្ខជន ក្នុងករណីពុំអាចសម្របសម្រួលបាន ។

*** នីតិវិធីសំរាប់ការបោះឆ្នោតជ្រើសរើសបេក្ខជនក្រុមប្រឹក្សាឃុំ-សង្កាត់**

គណៈកម្មការគណបក្សស្រុក-ខណ្ឌរៀបចំបញ្ជីបេក្ខជនក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវបញ្ជាក់ប្រាប់អ្នកបោះឆ្នោត អំពីចំនួនបេក្ខជនដែលត្រូវជ្រើសរើស មុននឹងដំណើរការបោះឆ្នោត ។ ការបោះឆ្នោតជ្រើសរើសបេក្ខជនក្រុមប្រឹក្សាឃុំ-សង្កាត់ ធ្វើឡើងបន្ទាប់ពីប្រធានគណៈកម្មការគណបក្សស្រុក-ខណ្ឌរៀបចំបញ្ជីបេក្ខជនក្រុមប្រឹក្សាឃុំ-សង្កាត់ បង្ហាញបញ្ជីរាយនាមសមាជិកគណបក្ស ដែលបានដាក់ពាក្យសុំឈរឈ្មោះជាបេក្ខជនក្រុមប្រឹក្សាឃុំ-សង្កាត់ ។ សមាជិកគណបក្សដែលជាអ្នកបោះឆ្នោត មានសិទ្ធិគូសយកនូវបេក្ខជនណាដែលខ្លួនពេញចិត្ត ។ ឈ្មោះដែលទទួលបានការគាំទ្រនៅលើបញ្ជីរាយនាម មិនត្រូវមានចំនួនលើសពីចំនួនដែលត្រូវជ្រើសរើស(ចំនួនបានកំណត់)នោះទេ ។ បើលើសសន្លឹកឆ្នោតនោះត្រូវទុកជាមោឃៈ ។ សមាជិកគណបក្សរូបណាដែលបានទទួលសម្លេងគាំទ្រច្រើនជាងគេ តាមលំដាប់លំដោយ នឹងក្លាយទៅជាបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសបេក្ខជនក្រុមប្រឹក្សាឃុំ-សង្កាត់ ។ ក្នុងករណីដែលបេក្ខជនរូបណាទទួលបានសន្លឹកឆ្នោតស្មើគ្នា បើបេក្ខជននោះជាបុរស និងស្ត្រី អាទិភាពត្រូវបានទៅបេក្ខជនស្ត្រី, បើបេក្ខជននោះមានភេទដូចគ្នា ត្រូវធ្វើការចាប់ឆ្នោត ។

លទ្ធផលនៃការបោះឆ្នោតនេះ គណៈកម្មការគណបក្សស្រុក-ខណ្ឌរៀបចំបញ្ជីបេក្ខជនក្រុមប្រឹក្សាឃុំ-សង្កាត់ អាចយកធ្វើជាមូលដ្ឋាន សំរាប់រៀបចំលំដាប់លេខរៀងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ដោយរៀបចំតាមសម្លេងឆ្នោតដែលបេក្ខជនម្នាក់ៗទទួលបាន ។

កាលបរិច្ឆេទ និងទីកន្លែងបោះឆ្នោត កំណត់ដោយគណៈកម្មការគណបក្សស្រុក-ខណ្ឌរៀបចំបញ្ជីបេក្ខជនក្រុមប្រឹក្សាឃុំ-សង្កាត់ តាមសភាពការណ៍ជាក់ស្តែង ។

សមាជិកក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ ដែលទទួលស្គាល់ដោយអគ្គលេខាធិការគណបក្ស និងក្រុមប្រឹក្សាគណបក្សភូមិនៅក្នុងឃុំ-សង្កាត់សាមី ដែលទទួលស្គាល់ដោយប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង មានសិទ្ធិចូលរួមក្នុងការបោះឆ្នោតជ្រើសរើសបេក្ខជនក្រុមប្រឹក្សាឃុំ-សង្កាត់ និងជ្រើសរើសលំដាប់លេខរៀងបេក្ខជនក្រុមប្រឹក្សាឃុំ-សង្កាត់ ។ ក្នុងករណីពិសេស គណៈកម្មការគណបក្សស្រុក-ខណ្ឌរៀបចំបញ្ជីបេក្ខជនក្រុមប្រឹក្សាឃុំ-សង្កាត់ អាចស្នើសុំមកប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ដើម្បីអោយសមាជិកគណបក្សដែលមានឈ្មោះនៅក្នុងបញ្ជីសមាជិកគណបក្សភូមិ ឬប្រជាពលរដ្ឋនៅក្នុងភូមិចូលរួមបោះឆ្នោតជ្រើសរើសបេក្ខជនក្រុមប្រឹក្សាឃុំ-សង្កាត់ ។

**២-២_ការរៀបចំបញ្ជីលំដាប់លេខរៀងបេក្ខជនក្រុមប្រឹក្សាឃុំ-សង្កាត់**

ការរៀបចំបញ្ជីលំដាប់លេខរៀងបេក្ខជនក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវផ្អែកលើគុណសម្បត្តិ ការងារ ការលះបង់ សេចក្តីក្លាហាន សមត្ថភាព និងប្រជាប្រិយភាពរបស់បុគ្គល ហើយធានាឯកភាពផ្ទៃក្នុងនៃបេក្ខជនទាំងអស់ និងក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ ។ ដើម្បីអនុវត្តនូវគោលការណ៍នេះ គណៈកម្មការគណបក្សស្រុក-ខណ្ឌរៀបចំបញ្ជីបេក្ខជនក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវ :

_ពិភាក្សាជាមួយបេក្ខជន ក្រុមប្រឹក្សាគណបក្សភូមិ និងក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់សាមី ដើម្បីវាយតម្លៃអំពីគុណសម្បត្តិ គុណវិបត្តិ ការលះបង់ សមត្ថភាព ប្រជាប្រិយភាពនៃបេក្ខជនម្នាក់ៗ មុនការរៀបចំលំដាប់លេខរៀង ឬ

_រៀបចំធ្វើការបោះឆ្នោតតាមនីតិវិធីដែលបានចែងខាងលើ  ក្នុងករណីដែលមានការតវ៉ាពុំអាចសម្រុះសម្រួលបាន ។

**២-៣_ការទទួលពាក្យបណ្តឹង និងដោះស្រាយពាក្យបណ្តឹង**

គណៈកម្មការគណបក្សស្រុក-ខណ្ឌរៀបចំបញ្ជីបេក្ខជនក្រុមប្រឹក្សាឃុំ-សង្កាត់ មានតួនាទីទទួលពាក្យបណ្តឹង និងដោះស្រាយពាក្យបណ្តឹង ពាក់ព័ន្ធនឹងការរៀបចំលំដាប់លេខរៀងបញ្ជីបេក្ខជនឈរឈ្មោះក្រុមប្រឹក្សាឃុំ-សង្កាត់ ដោយបកស្រាយពន្យល់មូលហេតុ ដល់អ្នកប្តឹងជំទាស់ ឬប្តឹងតវ៉ា ឬរៀបចំលំដាប់លេខរៀងឡើងវិញភ្លាមៗ តាមរយៈការបោះឆ្នោត ប្រសិនបើពិនិត្យឃើញមានភាពមិនប្រក្រតី ។

**៣_ថវិកាសំរាប់រៀបចំបញ្ជីបេក្ខជនក្រុមប្រឹក្សាឃុំ-សង្កាត់**

ថវិកាសំរាប់ចំណាយការរៀបចំបញ្ជីបេក្ខជនក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវធានារ៉ាប់រងដោយក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង និងប្រធានក្រុមទ្រទ្រង់ការងារគណបក្សប្រចាំស្រុក-ខណ្ឌ ឬឃុំ-សង្កាត់សាមី ។

## III_ការរៀបចំបញ្ជីបេក្ខជនតំណាងរាស្ត្រ

**១_លក្ខខណ្ឌសំរាប់ការឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ**

ដើម្បីឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រនៅមណ្ឌលខេត្ត-ក្រុងណាមួយ  សកម្មជនគណបក្សគ្រប់រូបចាំបាច់ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម :

_មានភាពស្មោះត្រង់ ជឿជាក់លើគោលការណ៍ និងគោលនយោបាយគណបក្ស និងគោរពប្រតិបត្តិបាវចនារបស់គណបក្ស

_មានសមត្ថភាព មានភាពប៉ិនប្រសព្វក្នុងការកៀងគរអ្នកបោះឆ្នោត និងមានការយល់ដឹងទូលំទូលាយអំពីបញ្ហាសង្គម និងនយោបាយ

_ចូលរួមយ៉ាងសកម្ម និងជាក់ស្តែង រយៈពេលយ៉ាងតិច២ឆ្នាំមុនការបោះឆ្នោត ក្នុងការជួយសកម្មភាពការងារគណបក្សប្រកបដោយប្រសិទ្ធភាពនៅក្នុងខេត្ត-ក្រុងណាមួយ  ដូចជាជួយការងារកំណែទំរង់រចនាសម្ព័ន្ធគណបក្សមូលដ្ឋាន ការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងក្របខ័ណ្ឌជាប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ជាប្រធានក្រុមទ្រទ្រង់ការងារគណបក្សប្រចាំស្រុក-ខណ្ឌ ឬឃុំ-សង្កាត់ ជាសមាជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ជាសមាជិកក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌ ជាសមាជិកក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ និងជាប្រធាន អនុប្រធានការិយាល័យនានា នៃក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ឬបានជួយការងារគណបក្សនៅទីស្នាក់ការកណ្តាលក្នុងក្របខ័ណ្ឌជាថ្នាក់ដឹកនាំនាយកដ្ឋាន និងខុទ្ទកាល័យប្រធានគណបក្ស

_គោរព និងធានាបង់ថវិកាសំរាប់យុទ្ធនាការបោះឆ្នោតតាមគំរោងរបស់ក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងនីមួយៗ ។

សកម្មជនគណបក្សរូបណាដែលមានបំណងឈរឈ្មោះ ជាបេក្ខជនតំណាងរាស្ត្រនៅមណ្ឌលខេត្ត-ក្រុងណាមួយ ត្រូវដាក់ពាក្យសុំឈរឈ្មោះមកអគ្គលេខាធិការគណបក្ស តាមរយៈប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង រយៈពេលយ៉ាងយូរមួយឆ្នាំមុនការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ ទំរង់បែបបទ នៃពាក្យសុំឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ កំណត់ដោយអគ្គលេខាធិការគណបក្ស ។

## ២_ការជ្រើសរើសបេក្ខជនតំណាងរាស្ត្រ

ការជ្រើសរើសបេក្ខជនតំណាងរាស្ត្រសំរាប់មណ្ឌលខេត្ត-ក្រុងនីមួយៗ ជាសមត្ថកិច្ចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស ដោយពិភាក្សាជាមួយប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងសាមី ឬជាមួយមន្ត្រីគណបក្សពាក់ព័ន្ធ បើមានការចាំបាច់ ។ អគ្គលេខាធិការគណបក្សត្រូវបញ្ជូនពាក្យសុំឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រសំរាប់មណ្ឌលខេត្ត-ក្រុងនីមួយៗ ទៅគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស ។ គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្សបន្ទាប់ពីមានការពិភាក្សាជាមួយប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងសាមី ឬជាមួយមន្ត្រីគណបក្សពាក់ព័ន្ធ ត្រូវសំរេចលើពាក្យសុំឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រសំរាប់មណ្ឌលខេត្ត-ក្រុងនីមួយៗ រយៈពេលយ៉ាងយូរ១០ខែមុនការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដោយប្រកាសទទួលស្គាល់បេក្ខជនរូបណាមួយថាមានលក្ខណសម្បត្តិអាចឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ ។

ចំពោះខេត្ត-ក្រុងណាដែលមានសកម្មជនគណបក្សដាក់ពាក្យសុំឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ មានចំនួនតិចជាងចំនួនបេក្ខជនដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស ត្រូវសហការជាមួយប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងសាមី ធ្វើការជ្រើសរើសបេក្ខជនដែលមានលក្ខណសម្បត្តិសមស្របបន្ថែម ដើម្បីបំពេញចំនួនបេក្ខជនដែលច្បាប់បានកំណត់ ។

ផ្ទុយទៅវិញ ចំពោះខេត្ត-ក្រុងណាដែលមានសកម្មជនគណបក្សដាក់ពាក្យសុំឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ ហើយដែលបានបំពេញតាមលក្ខខណ្ឌសំរាប់ការឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ មានចំនួនច្រើនជាងចំនួនបេក្ខជនដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្សត្រូវសហការជាមួយប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងសាមី ដើម្បីសម្របសម្រួលរកបេក្ខជនណាដែលស្ម័គ្រចិត្តដកខ្លួនចេញពីការឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ ឬរៀបចំធ្វើការបោះឆ្នោតជ្រើសរើសបេក្ខជន ក្នុងករណីពុំអាចសម្របសម្រួលបាន ។

### *ការបោះឆ្នោតជ្រើសរើសបេក្ខជនតំណាងរាស្ត្រ

ការរៀបចំការបោះឆ្នោតជ្រើសរើសបេក្ខជនតំណាងរាស្ត្រ ជាសមត្ថកិច្ចរបស់គណៈកម្មការមួយ ដែលមានសមាសភាពដូចតទៅ :

| | |
|---|---|
| _អគ្គលេខាធិការគណបក្ស ឬអគ្គលេខាធិការរង | ជាប្រធាន |
| _សមាជិកគណៈកម្មាធិការនាយក ១រូប | ជាសមាជិក |
| _សមាជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងសាមី ដែលមិនមែនជាបេក្ខជន ១រូប | ជាសមាជិក |

គណៈកម្មការរៀបចំការបោះឆ្នោតជ្រើសរើសបេក្ខជនតំណាងរាស្ត្រ ត្រូវបញ្ជាក់ប្រាប់អ្នកបោះឆ្នោតអំពីចំនួនបេក្ខជនដែលត្រូវជ្រើសរើស មុននឹងដំណើរការបោះឆ្នោត ។ ការបោះឆ្នោតជ្រើសរើសបេក្ខជនតំណាងរាស្ត្រធ្វើឡើងបន្ទាប់ពីប្រធានគណៈកម្មការរៀបចំការបោះឆ្នោត បង្ហាញបញ្ជីរាយនាមសកម្មជនគណបក្ស ដែលបានដាក់ពាក្យសុំឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ ។ សកម្មជនគណបក្សដែលជាអ្នកបោះឆ្នោតមានសិទ្ធិគូសយកនូវបេក្ខជនណាដែលខ្លួនពេញចិត្ត ។ ឈ្មោះដែលទទួលបានការគាំទ្រនៅលើបញ្ជីរាយនាម មិនត្រូវមានចំនួនលើសពីចំនួនដែលត្រូវជ្រើសរើស (ចំនួនបានកំណត់)នោះទេ ។ បើលើសសន្លឹកឆ្នោតនោះត្រូវទុកជាមោឃៈ ។ សកម្មជនគណបក្សរូបណា ដែលបានទទួលសម្លេងគាំទ្រច្រើនជាងគេតាមលំដាប់លំដោយ នឹងក្លាយជាបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

កាលបរិច្ឆេទ និងទីកន្លែងបោះឆ្នោត កំណត់ដោយគណៈកម្មការរៀបចំការបោះឆ្នោតជ្រើសរើសបេក្ខជនតំណាងរាស្ត្រ តាមសភាពការណ៍ជាក់ស្តែង ។

សមាជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ដែលទទួលស្គាល់ដោយប្រធានគណបក្ស សមាជិកក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌ និងប្រធានក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ ដែលទទួលស្គាល់ដោយអគ្គលេខាធិការគណបក្ស មានសិទ្ធិចូលរួមក្នុងការបោះឆ្នោតជ្រើសរើសបេក្ខជនតំណាងរាស្ត្រសំរាប់មណ្ឌលខេត្ត-ក្រុងសាមី ។

សកម្មជនគណបក្សរូបណាដែលត្រូវបានទទួលស្គាល់ជាបេក្ខជនតំណាងរាស្ត្រហើយ បែរជាអសកម្មការងារ មិនគោរពគោលការណ៍ និងគោលនយោបាយគណបក្ស ឬបង្កើតបញ្ហាផ្សេងៗដែលប៉ះពាល់ដល់ផលប្រយោជន៍គណបក្ស គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស នឹងលុបបេក្ខភាពរបស់បេក្ខជននោះវិញ ។

*** ថវិកាសំរាប់ចំណាយក្នុងការរៀបចំការបោះឆ្នោតជ្រើសរើសបេក្ខជនតំណាងរាស្ត្រ ត្រូវធានាប៉ាប់រង ដោយសកម្មជនគណបក្ស ដែលឈរឈ្មោះប្រកួតប្រជែងជាបេក្ខជនតំណាងរាស្ត្រក្នុងចំណែកស្មើគ្នា ។**

**៣_ការរៀបចំបញ្ជី និងលំដាប់លេខរៀងបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ**

ការរៀបចំបញ្ជី និងលំដាប់លេខរៀងបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ សំរាប់មណ្ឌលខេត្ត-ក្រុងនីមួយៗ នឹងរៀបចំដោយគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស ដោយពិភាក្សាជាមួយប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងសាមី ឬជាមួយមន្ត្រីគណបក្សពាក់ព័ន្ធ រយៈពេលមួយខែមុនការបញ្ជូនបញ្ជីបេក្ខជនតំណាងរាស្ត្រទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ការរៀបចំបញ្ជី និងលំដាប់លេខរៀងបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ សំរាប់មណ្ឌលខេត្ត-ក្រុងនីមួយៗ ត្រូវផ្អែកលើគុណសម្បត្តិ ស្នាដៃ ការលះបង់ និងប្រសិទ្ធភាពការងារ ហើយជាពិសេសការគោរពនូវការសន្យាបង់ថវិកាសំរាប់យុទ្ធនាការបោះឆ្នោតតាមគំរោងដែលបានកំណត់ ។ ដើម្បីអនុវត្តនូវគោល-ការណ៍នេះ គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្សត្រូវពិភាក្សាជាមួយប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងសាមី ឬជាមួយមន្ត្រីគណបក្សពាក់ព័ន្ធ ធ្វើការវាយតម្លៃអំពីគុណសម្បត្តិ គុណវិបត្តិ ស្នាដៃ ការលះបង់ និងប្រសិទ្ធភាពការងារនៃបេក្ខជនម្នាក់ៗ ក្នុងការ រៀបចំលំដាប់លេខរៀង ឬរៀបចំធ្វើការបោះឆ្នោត តាមនីតិវិធីដែលបានចែងខាងលើ ក្នុងករណីមានការតវ៉ា ដែលមិនអាចសម្របសម្រួលបាន ។

ការរៀបចំការបោះឆ្នោតដើម្បីរៀបលំដាប់លេខរៀងនេះ អនុវត្តសំរាប់ :

_បេក្ខជនណាដែលតវ៉ាមិនសុខចិត្តនឹងលំដាប់លេខរៀងរបស់បេក្ខជនផ្សេងទៀត

_រៀបចំលំដាប់លេខរៀងនៅលើបញ្ជីទាំងមូល ក្នុងករណីមានការស្នើសុំពីបេក្ខជនចំនួន៣/៤ នៃបេក្ខជនទាំងអស់នៅក្នុងមណ្ឌលខេត្ត-ក្រុងនីមួយៗ

ការរៀបចំការបោះឆ្នោតនេះ លុះត្រាតែមានការយល់ព្រមពីគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស ។

បេក្ខជនដែលទទួលបានការគាំទ្រច្រើនជាងគេពីអ្នកបោះឆ្នោតតាមលំដាប់លំដោយ ហើយបានបំពេញកាតព្វកិច្ចបង់ថវិកាជាក់ស្តែងសំរាប់យុទ្ធនាការបោះឆ្នោតតាមគំរោង ត្រូវបានតែងតាំងជាបេក្ខជនតំណាងរាស្ត្រសំរាប់មណ្ឌលខេត្ត-ក្រុងនោះ ។ ក្នុងករណីដែលបេក្ខជនរូបណាទទួលបានសន្លឹកឆ្នោតស្មើគ្នា បើបេក្ខជននោះជាបុរស និងស្ត្រី អាទិភាពត្រូវបានទៅបេក្ខជនស្ត្រី, បើបេក្ខជននោះមានភេទដូចគ្នា ត្រូវធ្វើការចាប់ឆ្នោត ។

*** ថវិកាសំរាប់ចំណាយក្នុងការរៀបចំការបោះឆ្នោតរៀបលំដាប់លេខរៀងបេក្ខជនតំណាងរាស្ត្រ ត្រូវធានាប៉ាប់រង ដោយសកម្មជនគណបក្ស ដែលឈរឈ្មោះប្រកួតប្រជែងជាបេក្ខជនតំណាងរាស្ត្រ ហើយដែលស្នើសុំឲ្យមានការបោះឆ្នោត ។**

៤_ការទទួលពាក្យបណ្ដឹង និងដោះស្រាយពាក្យបណ្ដឹង

គណៈកម្មការរៀបចំការបោះឆ្នោតជ្រើសរើស និងរៀបចំបញ្ជីលំដាប់លេខរៀងបេក្ខជនតំណាងរាស្ត្រ មានតួនាទីទទួលពាក្យបណ្ដឹង និងដោះស្រាយពាក្យបណ្ដឹង ពាក់ព័ន្ធនឹងការជ្រើសរើស និងរៀបចំលំដាប់លេខរៀងបេក្ខជនតំណាងរាស្ត្រ ដោយបកស្រាយពន្យល់មូលហេតុដល់អ្នកប្ដឹងជំទាស់ ឬប្ដឹងតវ៉ា ឬរៀបចំការបោះឆ្នោតឡើងវិញភ្លាម ប្រសិនបើពិនិត្យឃើញមានភាពមិនប្រក្រតី ។

## IV- ទោសប្បញ្ញត្តិ

បេក្ខជនគ្រប់រូប ឬអ្នកគាំទ្របេក្ខជនរូបណាក៏ដោយ នឹងត្រូវព្រមាន ឬដកហូតសិទ្ធិក្នុងការបោះឆ្នោត និងសិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោតឲ្យខ្លួន គ្រប់ស្ថាប័នទាំងអស់របស់គណបក្ស ក្នុងករណីបានប្រព្រឹត្តអំពើណាមួយដូចខាងក្រោម :

- ប្រើប្រាស់លុយកាក់ សំភារៈ ឬធ្វើពិធីជប់លៀងដល់អ្នកបោះឆ្នោតដើម្បីអូសទាញសម្លេង ឬ
- សន្យាប្រើឥទ្ធិពលរបស់ខ្លួនដើម្បីផ្ដល់នូវមុខតំណែងណាមួយក្នុងគោលបំណងទិញទឹកចិត្តអ្នកបោះឆ្នោត ឬ
- គំរាមកំហែង សម្លុត ឬបំភិតបំភ័យអ្នកបោះឆ្នោត ឬ
- ទទួលសំណូកសូកប៉ាន់ ដើម្បីគៀងគររកសម្លេងឆ្នោតឲ្យបេក្ខជនណាមួយ ឬ
- ប៉ុនប៉ងបំផ្លាញលទ្ធផលនៃការបោះឆ្នោត ។

***ការរៀបចំបេក្ខជនក្រុមប្រឹក្សាសង្កាត់ និងការរៀបចំបេក្ខជនតំណាងរាស្ត្រ នៅទីក្រុងភ្នំពេញ ក៏ដូចជាការជ្រើសតាំងប្រធានក្រុមប្រឹក្សាគណបក្សក្រុងភ្នំពេញ ប្រព្រឹត្តទៅតាមនីតិវិធីមួយដោយឡែក ដែលកំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស ។

សេចក្ដីណែនាំនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែមិថុនា ឆ្នាំ២០០៦*

ប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស

សម រង្ស៊ី